# មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម
# THE CENTER FOR SOCIAL DEVELOPMENT

## ម.អ.ស. ពង្រីកការសម្របសម្រួលសម្រាប់អ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជា ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅ អ.វ.ត.ក.

បន្ថែមពីលើ ***ក្រុមអ្នកកំព្រា***, ឥឡូវនេះមាន ***ក្រុមអ្នកមេម៉ាយ/ពោះម៉ាយ***, ***ក្រុមអ្នកជាប់ឃុំឃាំង***

និងកំពុងពិចារណាទៅលើ ***ក្រុមទាហានកុមារ***

---

## សេចក្តីថ្លែងការណ៍ព័ត៌មាន

---

ភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៨ ៖ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (ម.អ.ស.) មានក្តីរីករាយ សូមជម្រាបជូនដំណឹងថា ម.អ.ស. នឹងពង្រីកការសម្របសម្រួលសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម ដែលមានចំណាប់អារម្មណ៍ ក្នុងការក្លាយខ្លួនជា ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បន្ថែមលើការដាក់ពាក្យសុំជា ***ក្រុមអ្នកកំព្រា*** ដោយរួមបញ្ចូល ***ក្រុមអ្នកមេម៉ាយ/ពោះម៉ាយ, ក្រុមអ្នកជាប់ឃុំឃាំង*** ហើយអាចនឹងបញ្ចូល ***ក្រុមទាហានកុមារ*** ។

នៅក្នុងខែកញ្ញា ឆ្នាំ២០០៧, អ្នកនាង សេង ធារី ដែលជានាយិកាប្រតិបត្តិនៃ ម.អ.ស. បានក្លាយទៅជាអ្នកដាក់ពាក្យសុំមុនដំបូងគេបំផុត និងត្រូវបានទទួលស្គាល់ដោយ អ.វ.ត.ក. ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ហើយបានចូលរួមជាមួយក្រុមអ្នកកំព្រា ដែលសំដៅទៅដល់អ្នកដែលបាត់បង់ឪពុក ឬ ម្តាយ ឬ ទាំងឪពុកនិងម្តាយ នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ក្នុងនាមជាសមាជិកនៅក្នុង **ក្រុមអ្នកកំព្រា** អ្នកនាង សេង ធារី បានធ្វើការសម្របសម្រួលក្នុងការប្រមូលផ្តុំអ្នកកំព្រាដែលមានការឈឺចាប់និងសង្ឃឹមរួមគ្នា, ថារួមសម្លេងគ្នា ក្នុងការចោទប្រកាន់ជាផ្លូវការ ចំពោះមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់កំពុងជាប់ឃុំ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឧក្រិដ្ឋកម្មសង្គ្រាម ជាដើម ។

ចាប់តាំងពីពេលនោះមក ម.អ.ស. បានរៀបចំសិក្ខាសាលាពិស្តារ សម្រាប់ជនរងគ្រោះដែលមានចំណាប់អារម្មណ៍ ក្នុងការយល់ដឹងពីដំណើរការដាក់ពាក្យស្នើសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ភ្ជាប់ជាមួយនឹងកម្មវិធីវេទិកាសាធារណៈស្តីពី “យុត្តិធម៌ និង ការបង្រួបបង្រួមជាតិ” ។ ម.អ.ស. បានរៀបចំសិក្ខា

សាលាចំនួន១៣ នៅក្នុងខេត្តចំនួន១១ និងនៅទីក្រុងភ្នំពេញ ដោយក្នុងនោះមានអ្នកចូលរួមជាមធ្យមចំនួន២០ នាក់សម្រាប់សិក្ខាសាលានីមួយៗ ។

ម.អ.ស. បានរកឃើញថាសម្រាប់អ្នកចូលរួមក្នុងសិក្ខាសាលាទាំងនេះ មានជនរងគ្រោះប្រហែលពាក់កណ្ដាលស្របនឹងលក្ខខណ្ឌអាចចូលរួមនៅក្នុង**ក្រុមអ្នកកំព្រា** ។ ជនរងគ្រោះដែលមានបទពិសោធន៍ផ្សេងពីក្រុមអ្នកកំព្រា នៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩, ម.អ.ស. បានស្នើបញ្ជូនទៅអង្គការអាដហុក និងអង្គការដទៃទៀត ដោយសង្ឃឹមថានឹងមានការបង្កើតក្រុមផ្សេងទៀតសម្រាប់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ។ ២ឆ្នាំក្រោយពីនោះមក យើងមិនឃើញ មានការបង្កើតក្រុមផ្សេងទៀតសម្រាប់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ។ ដូចនេះហើយ ទើបបានជា ម.អ.ស. សម្រេចពង្រីកកិច្ចខំប្រឹងប្រែងរបស់ខ្លួនក្នុងការបង្កើត និងជួយសម្របសម្រួលបង្កើតក្រុមភាគីដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងៗទៀត មានជាអាទិ៍ ៖

- ***ក្រុមអ្នកកំព្រា*** ៖ ជាជនរងគ្រោះនៃរបបខ្មែរក្រហម ដែលបានបាត់បង់ឪពុក ឬ ម្ដាយ ឬ ទាំងឪពុកនិងម្ដាយ នៅក្នុងរបបខ្មែរក្រហម ។
- ***ក្រុមអ្នកមេម៉ាយ/ពោះម៉ាយ*** ៖ ជាជនរងគ្រោះនៃរបបខ្មែរក្រហម ដែលបានបាត់បង់ ប្ដី ឬ ប្រពន្ធ នៅក្នុងរបបខ្មែរក្រហម និង
- ***ក្រុមអ្នកជាប់ឃុំឃាំង*** ៖ ជាជនរងគ្រោះនៃរបបខ្មែរក្រហម ដែលត្រូវបានគេដាក់ឃុំ ក្នុងមន្ទីរឃុំឃាំងយ៉ាងហោចណាស់មួយ ក្នុងចំណោមមន្ទីរឃុំឃាំងទាំង១៩៦ ក្នុងរបបខ្មែរក្រហម ។

ទន្ទឹមគ្នានេះផងដែរ ម.អ.ស. កំពុងធ្វើការលើ បញ្ហា**ទាហានកុមារ**ពីរបបខ្មែរក្រហមក្នុងកម្មវិធីបង្រួបបង្រួមផ្សះផ្សា របស់ ម.អ.ស. ហើយដែលគម្រោងនេះ ដឹកនាំដោយលោកស្ដេហ្វាន ឃីសេល (Stefan KIESEL) ទីប្រឹក្សាមកពីសេវាកម្មអភិវឌ្ឍន៍អាឡឺម៉ង់ (DED) ដែលមានបទពិសោធន៍ធ្វើការជាមួយទាហានកុមារ នៅប្រទេសសេរ៉ាឡេអូន ។ នៅពេលនេះ យើងកំពុងធ្វើការសិក្សាស្រាវជ្រាវពីការពាក់ព័ន្ធ និងការបញ្ជាក់ផ្នែកច្បាប់ ទាក់ទងនឹងបុគ្គលដែលត្រូវគេជ្រើសរើសតាំងពីវ័យកុមារ ឲ្យចូលរួមប្រយុទ្ធនៅក្នុងរបបខ្មែរក្រហមនោះ ដើម្បីឲ្យពួកគេបានចូលរួម និងក្លាយទៅជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី ។

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមជឿជាក់ថា ដំណើរការរៀបចំជាក្រុមនេះ នឹងមានភាពល្អប្រសើរបំផុតនៅពេលដែលវាផ្ដើមគំនិតចេញមកពីជនរងគ្រោះខ្លួនឯង និងជឿជាក់ថា ការរៀបចំជាក្រុមភាគីដើមបណ្ដឹងរដ្ឋប្បវេណីឲ្យចេញជា “សកម្មភាពក្រុម” បែបនេះ នឹងបង្កើនអំណាចនិងតំណាងរបស់ជនរងគ្រោះនៅចំពោះមុខតុលាការ ។ លើសពីនេះទៅទៀត សកម្មភាពក្រុមភាគីដើមបណ្ដឹងរដ្ឋប្បវេណី ទាំងនេះ នឹងកាត់បន្ថយការប្រើប្រាស់និងការចំណាយផ្នែករដ្ឋបាលដែលមិនចំគោលដៅ សម្រាប់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ។ ដូចនេះការពង្រីកអាណត្តិរបស់ ម.អ.ស. ក្នុងការបញ្ចូលក្រុមបន្ថែមទៀតនេះ នឹងអនុញ្ញាតិឲ្យ ម.អ.ស. ពង្រីកការ

ប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះការរៀបចំនៅតាមមូលដ្ឋាន និងពង្រីកផលប្រយោជន៍នៃវេទិកាសាធារណៈ និងសិក្ខាសាលាទាំងនោះ ឲ្យបានទៅដល់មនុស្សកាន់តែច្រើនថែមទៀត ។

ខុសពីកាលមុនដែលការរៀបចំសិក្ខាសាលាដើមបណ្តឹងរដ្ឋប្បវេណីនេះមិនបើកចំហរទាំងស្រុង ឥឡូវនេះ ម.អ.ស. បានចាប់ផ្តើមបើកសិក្ខាសាលានេះ ជាចំហរទាំងស្រុងជាសាធារណៈ ដោយការរៀបចំសិក្ខាសាលាដែលមានរយៈពេល ៤-៥ ម៉ោងនោះ ផ្តោតទៅលើ អ.វ.ត.ក. និង ដំណើរការដើម្បីចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនបានធ្វើឲ្យលេចចេញនូវព័ត៌មានសម្ងាត់របស់ជនរងគ្រោះឡើយ ។ ជាងនេះទៅទៀត អ្នកចូលរួមបានបញ្ជាក់បង្ហាញ ជាឯកច្ឆ័ន្ទ ថាពួកគាត់ចង់ឲ្យរឿងទុក្ខសោករបស់ពួកគាត់ត្រូវបានដឹងលឺ និងមានការទទួលស្គាល់ចំពោះការឈឺចាប់ទាំងអស់នោះ ។ ដោយសារតែមានការលើកឡើងបែបនេះ យើងបន្តតាំងចិត្តក្នុងការតំកល់សុខុមាលភាពរបស់អ្នកចូលរួមទាំងអស់ ជាការសំខាន់លើសអ្វីៗទាំងអស់ ។ ដូច្នេះហើយ យើងនឹងរក្សាការពារ ភាពសម្ងាត់ សម្រាប់អ្នកដែលសុំឲ្យមានការរក្សាភាពសម្ងាត់ នៅពេលដែលពួកគាត់បន្តចូលសំណួរ និងមតិយោបល់ដែលមានលក្ខណៈកាន់តែស៊ីជម្រៅថែមទៀត នៅក្នុងដំណើរការដែលយើងមានការពាក់ព័ន្ធជាមួយពួកគាត់ ។

ម.អ.ស. សូមថ្លែងអំណរគុណដល់សេវាកម្មអភិវឌ្ឍន៍អាឡឺម៉ង់ (DED) និងអង្គការដៃកូនា/ស៊ីដា (Diakonia/SIDA) ដែលបានផ្តល់ជំនួយដ៏សប្បុរស ក្នុងការគាំទ្រដល់កិច្ចខំប្រឹងប្រែងនេះ, សូមអរគុណដល់ស្ថានទូតអង់គ្លេស ដែលបានផ្តល់ការឧបត្ថម្ភខ្សែភាពយន្ត "ដល់ពេលរកយុត្តិធម៌", សូមអរគុណដល់ស្ថានទូតកាណាដា ក្នុងការផ្តល់មូលនិធិដែលបានអនុញ្ញាតិឲ្យយើងចាប់ផ្តើម ការប្រមូលពាក្យស្នើសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនេះនៅតាមបណ្តាខេត្តមួយចំនួន ។ ម.អ.ស. ក៏សូមថ្លែងអំណរគុណ និងសូមប្រកាសម្ចាស់ជំនួយថ្មីមួយទៀតគឺ មូលនិធិ ម៉ាកខាធើ (The John D. and Catherine T. MacArthur Foundation) ដែល ម.អ.ស. បានទទួលសម្រាប់ការងារផ្សព្វផ្សាយដល់ជនរងគ្រោះ ជាពិសេសដល់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងក្រុមភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ ។

---

សម្រាប់ពត៏មានបន្ថែម សូមចូលទៅកាន់គេហទំព័រ **[www.csdcambodia.org](http://www.csdcambodia.org)** *"Public Forum" ("Justice & National Reconciliation","Civil Party of Orphans Class","Emotional Support Section")* និង/ឬ ទាក់ទង ៖

- លោក សុខ លាំង, អ្នកសម្របសម្រួលគម្រោងដើមបណ្តឹងរដ្ឋប្បវេណី/ជំនួយការកម្មវិធីជាន់ខ្ពស់
  012.588.081, sokleang@csdcambodia.org
- អ្នកនាង យឹម សុធារី, ជំនួយការចិត្តសាស្ត្រជាន់ខ្ពស់ ផ្នែកគាំទ្រផ្លូវចិត្ត
  012.733.644, sotheary@csdcambodia.org
- លោក ស្តេហ្វាន យីសែល (Mr. Stefan KIESEL), ទីប្រឹក្សាសន្តិភាពស៊ីវិលនៃសេវាកម្មអភិវឌ្ឍន៍អាឡឺម៉ង់ (DED)
  012.239.536, stefan@csdcambodia.org